**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣ ០១៤ ០៩២ ប.ក

# ប្រកាស
## ស្តីពី
## លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ៥០០០០ រៀល គំរូថ្មី

អនុលោមតាមអនុក្រឹត្យលេខ ១៧៥ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការចេញផ្សាយធនប័ត្រ ប្រភេទ **៥០០០០** រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនប័ត្រថ្មីនេះ មាន ដូចខាងក្រោម ៖

**ក- __លក្ខណៈទូទៅ__ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៥៥ មម និងទទឹង ៧២ មម
- ពណ៌ចម្បង គឺពណ៌ស្លាទុំ និងពណ៌ត្នោត

**ខ- __ផ្ទៃខាងមុខ__ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវ ព្រះឆាយាល័ក្ខណ៍មើលពីមុខបញ្ឆិតចំហៀងខាងឆ្វេងនៃអតីតព្រះមហាក្សត្រ **ព្រះបរមរតនកោដ្ឋ** ខាងឆ្វេងមានលេខ " ៥០០០០ " នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបជើងពានទ្រព្រះខ័នព័ទ្ធជុំវិញដោយកម្រងផ្កានិងក្បាច់ភ្ញីទេស និងនៅខាងក្រោមមានលេខ-មាលាដែលបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៧ ដែលយកគំរូតាមរូបចម្លាក់ថ្មនៅប្រាសាទបាលីលេយ្យជិតអង្គរធំ និងអក្សរ "ប្រាំម៉ឺនរៀល" ព្រមទាំងអក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោមនោះ និងមានខ្សែសុវត្ថិភាពទំហំ ១,២ មម កាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម។
- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " ព្រមទាំងលេខ-មាលាដែលត្រូវបានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហមនៅពីក្រោមនោះ និងជ្រុងខាងក្រោមមានលេខ " ៥០០០០ " និង " 50000 " នៅបន្ទាប់គ្នា ។
- **ផ្នែកខាងឆ្វេង** មានលេខ " 50000 " ព្រាលៗ ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងមាននិមិត្តសញ្ញាពិសេសសម្រាប់ជនពិការភ្នែកនៅពីក្រោមនោះ និងនៅកៀនខាងឆ្វេងមាន Hologram ទំហំ ១០ មម ប្រកបដោយបច្ចេកវិទ្យាទំនើបនិងស្តង់ដារកំរិតខ្ពស់ កាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម ។

**គ- __ផ្ទៃខាងខ្នង__ ៖**

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពប្រាសាទបាគងនៃក្រុមប្រាសាទរលួសក្នុងខេត្តសៀមរាប និងមានអក្សរ " ប្រាំម៉ឺនរៀល " នៅពីក្រោមនោះ ។

- **ផ្នែកខាងស្តាំ** មានរូបភាពកូនដំរីឈរទម្លាក់ប្រមោយចុះក្រោម ដែលយកគំរូតាមរូបចម្លាក់ថ្មនៅប្រាសាទកោះកេរ ក្នុងឃុំស្រយ៉ង់ខេត្តព្រះវិហារ និងមានលេខ " ៥០០០០ " នៅពីក្រោមនោះ ព្រមទាំងលេខ " 50000 " ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកៀនខាងស្តាំ ។

- **ផ្នែកខាងឆ្វេង** ខាងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " និង " NATIONAL BANK OF CAMBODIA " នៅបន្ទាប់គ្នា ព្រមទាំងលេខ " 2013 " នៅពីក្រោមនោះ និងនៅជ្រុងខាងក្រោមមានលេខ " ៥០០០០ " ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ៥០០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រគំរូថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភាន់ច្រឡំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៤

**ទេសាភិបាល**

ជា.ចាន់តូ